March 15, 2019

# របាយការណ៍សិទ្ធិមនុស្សប្រចាំឆ្នាំរបស់អាមេរិក៖ វប្បធម៌និទ្ទណ្ឌភាពបន្តរីករាលដាលនៅកម្ពុជា




*រដ្ឋមន្ត្រីការបរទេសអាមេរិកលោក ម៉ៃយ៍ ប៉ុមប៉េអូ* (Mike Pompeo) *ថ្លែងទៅអ្នកសារព័ត៌មាន ប្រកាសរបាយការណ៍សិទ្ធិមនុស្សលើកទី ៤៣ នៃប្រទេសជិត ២០០ នៅក្រសួងការបរទេស នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៩* Screenshot from the US State Department Website

***ដោយ មួង ណារ៉េត*** **RFA 2019-03-13**

*របាយការណ៍សិទ្ធិមនុស្សប្រចាំឆ្នាំ២០១៨ របស់សហរដ្ឋអាមេរិកស្ដីពីកម្ពុជា រកឃើញថា វប្បធម៌និទ្ទណ្ឌភាពនៅតែបន្តរីករាលដាលខ្លាំង។*

*ក្នុងរបាយការណ៍របស់ក្រសួងការបរទេសអាមេរិក ដែលចេញផ្សាយជាផ្លូវការ កាលពីថ្ងៃទី១៣ ខែមីនាថា វប្បធម៌និទ្ទណ្ឌភាព ឬការប្រព្រឹត្តិខុសច្បាប់ តែរួចទោសនេះ គឺដោយសាររបបលោក ហ៊ុន សែន មិនបានបង្ហាញកស្តុតាងអំពីការផ្តន្ទាទោស ទៅលើមន្ត្រីដែលប្រព្រឹត្តខុស ក្នុងការរំលោភសិទ្ធិមនុស្ស បំផ្លាញប្រជាធិបតេយ្យ និងអំពើពុករលួយ។*

បញ្ហារំលោភសិទ្ធិមនុស្ស ដែលកើតមាននៅកម្ពុជា រួមមាន ការចាប់ខ្លួន និងសម្លាប់មនុស្ស តាមតែអំពើចិត្ត ដែលប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាល ការជ្រៀតជ្រែកតាមតែអំពើចិត្ត លើជីវិតឯកជនរបស់ពលរដ្ឋខ្លួន រួមមានការតាមដានការបញ្ចេញមតិតាមប្រព័ន្ធផ្សព្វផ្សាយ និងការប្រើច្បាប់ព្រហ្មទណ្ឌមិនស្មើភាពគ្នា ការរឹតត្បិតសិទ្ធិសេរីភាព ក្នុងការតវ៉ាដោយសន្តិវិធី និងការរឹតត្បិតសិទ្ធិសេរីភាពក្នុងការជួបប្រជុំគ្នា ការរឹតត្បិតសិទ្ធិសេរីភាពនយោបាយ និងអំពើពុករលួយរាលដាល រួមទាំងវិស័យតុលាការជាដើម។

របាយការណ៍ ដដែលរកឃើញបន្ថែមថា ការបោះឆ្នោត ដោយផាត់ចោលគណបក្សប្រឆាំង និងការបន្តឃុំខ្លួន និងចោទប្រកាន់គណបក្សសង្គ្រោះជាតិលោក កឹម សុខា គឺជាផ្នែកមួយ នៃការបំផ្លាញប្រជាធិបតេយ្យ និងរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅកម្ពុជា។

អាស៊ីសេរី នៅតែមិនទាន់អាចសុំការឆ្លើយតបពីមន្ត្រីនាំពាក្យនៃរបបលោក ហ៊ុន សែន គឺលោក ផៃ ស៊ីផាន ជុំវិញរឿងនេះបាននៅឡើយទេ ដោយលោកស្នើឲ្យទាក់ទងទៅខាងគណៈកម្មាការសិទ្ធិមនុស្សនៃរបបនេះវិញ។ អាស៊ីសេរីព្យាយាមទាក់ទង ទៅលោក ជិន ម៉ាលីន ជាច្រើនលើកដែរ តែគ្មានអ្នកទទួលទូរស័ព្ទ។
រដ្ឋមន្ត្រីការបរទេសអាមេរិកលោក ម៉ៃយ៍ ប៉ុមប៉េអូ (Mike Pompeo) ថ្លែងទៅអ្នកសារព័ត៌មាន ប្រកាសរបាយការណ៍សិទ្ធិមនុស្សលើកទី ៤៣ នៃប្រទេសជិត ២០០ នៅក្រសួងការបរទេស កាលពីថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៩ ថាសហរដ្ឋអាមេរិកសង្ឃឹមថា របាយការណ៍នេះ នឹងជំរុញឲ្យរដ្ឋាភិបាល ដែលមានបញ្ហាសិទ្ធិមនុស្សទាំងនេះ កែប្រែការប្រព្រឹត្តិបំពានរបស់ខ្លួន ដើម្បីវិលមករកការគោរពសិទ្ធិមនុស្សឡើងវិញ។

រដ្ឋាភិបាលសហរដ្ឋអាមេរិក កន្លងមក បានបញ្ជាក់ជំហររបស់ខ្លួន ជាច្រើនលើកច្រើនសាររួចទៅហើយ ថាទំនាក់ទំនងរវាងប្រទេសទាំងពីរអាចប្រសើរឡើងវិញបាន ទាល់តែរបបលោក ហ៊ុន សែន ស្តារសិទ្ធិមនុស្ស និងប្រជាធិបតេយ្យឡើងវិញ៕